# ៤. ការចិញ្ចឹមជីវិតរបស់ប្រជាជនតាមដងទន្លេមេគង្គ

## ១. ប្រជាជននិងទន្លេ

ចំនួនប្រជាជនតាមអាងទឹកទន្លេមេគង្គលើសពី៦០លាននាក់។ ចំនួនប្រជាជននៃតំបន់អាងទន្លេមេគង្គនៅក្នុងប្រទេសនិមួយៗមាន៥,២លាននាក់នៅក្នុងប្រទេសឡាវ២៣,១លាននាក់នៅក្នុងប្រទេសថៃ,១៣លាននាក់នៅក្នុងប្រទេសកម្ពុជានិង ១៨,៧លាននាក់នៅក្នុងប្រទេសវៀតណាម។ ប្រមាណជា ៨៥% គឺជាសហគមន៍កសិកម្ម (គណៈកម្មាធិការទន្លេមេគង្គ(MRC)ឆ្នាំ ២០១០ទំព័រ៣១-៣២) ។ កសិកម្មការនេសាទការប្រមូលនៃជីវិតក្នុងទឹក និងបន្លែគឺជាសកម្មភាពសេដ្ឋកិច្ចដ៏សំខាន់របស់ប្រជាជនក្នុងអាងទន្លេ ហើយប្រហែលជា៦២,៦%នៃចំនួនប្រជាជនដែលធ្វើការនៅក្នុងតំបន់បង្កើតការរស់នៅរបស់ពួកគេជាមូលដ្ឋានបានពីការងារដែលទាក់ទងនឹងធនធានទឹក (គណៈកម្មាធិការទន្លេមេគង្គ(MRC)ឆ្នាំ ២០១០ទំព័រ៤៨) ។

ទន្លេមេគង្គមិនត្រឹមតែផ្គត់ផ្គង់ទឹកប្រើប្រាស់សំរាប់តំបន់ទីក្រុងប៉ុនណ្ណោះទេរ,វាក៏ជាប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនៅក្នុងសហគមន៍កសិកម្មក្នុងរដូវប្រាំងផងដែរ។ នៅក្នុងភូមិនានាតាមបណ្តោយដងទន្លេមេគង្គដែលស្ទើរតែរាល់ទឹកផឹកទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនិងទឹកសម្រាប់វិស័យកសិកម្មទាំងអស់ គឺពឹងអាស្រ័យលើទន្លេ។ ទន្លេនេះគឺមានសារៈសំខាន់ណាស់ ហើយក៏ជាកន្លែងសម្រាប់កុមារលេងផងដែរ។

នៅពេលដែលកម្រិតទឹកថយចុះនៅក្នុងរដូវប្រាំងតំបន់ក្លាយទៅជាស្ងួតខ្លាំងហើយមាត់ទន្លេក្លាយទៅជាទីកន្លែងដ៏សំខាន់មួយសម្រាប់ការធ្វើកសិកម្ម។ លើសពីនេះទៀតសោតដ៏ ជាប្រភពដ៏សំខាន់នៃប្រូតេអ៊ីនសម្រាប់សហគមន៍កសិកម្មគឺត្រីទឹកសាបដែលត្រូវបានគេចាប់នេសាទទាំងនៅតាមដងទន្លេនិងដៃទន្លេផ្សេងៗទៀត ក៏ដូចជាដីសើមនិងផ្លូវទឹកដែលតភ្ជាប់ទៅឱ្យពួកគេ។ នាពេលបច្ចុប្បន្ននេះមានត្រីប្រមាណជា៨៥០ប្រភេទដែលបានកំណត់ថា មាននៅក្នុងអាងទន្លេមេគង្គហើយភាគច្រើនអាចត្រូវបានបរិភោគ។ សណ្ឋានជីវិតក្នុងទឹករួមទាំងត្រីនិងកង្កែបគឺជាប្រភពប្រូតេអ៊ីនចំបងសំរាប់ប្រជាជន ព្រមទាំងជាប្រភពដ៏សំខាន់នៃការរកប្រាក់ចំណូលផងដែរ។ ប្រសិនបើរាប់បញ្ចូល ខាងអាជីវកម្មនិងពលកម្មតាមរដូវកាល គឺប្រជាជន៤០លាននាក់នៅក្នុងតំបន់នេះត្រូវបានចូលរួមនៅក្នុងឧស្សាហកម្មនេសាទនៃប្រព័ន្ធទឹកទន្លេមេគង្គ។ប្រហែល៤០%នៃចំនួនប្រជាជនរបស់ប្រទេសកម្ពុជាគឺអាស្រ័យនៅលើទឹកបឹងទន្លេសាប និងទីវាលដែលទឹកជំនន់នៅជុំវិញ (គណៈកម្មាធិការទន្លេមេគង្គ(MRC )ឆ្នាំ ២០១០ទំព័រ៤៩) ។



ទន្លេក៏ជាផ្លូវដឹកជញ្ជូនដ៏សំខាន់ដែរ។ វាមិនមែនជារឿងចម្លែកសម្រាប់មនុស្សពីភូមិជាច្រើននៅតាមដងទន្លេទាំងសងខាងនេះធ្វើអោយមានការទំនាក់

ទំនងឆ្ងាយពីគ្នានោះទេ។ កន្លងមកនៅក្នុងខេត្តអាបូណារាឆាថានី(UbonRatchathani)នៃប្រទេសថៃ មនុស្សដែលរស់នៅខាងថៃអាចធ្វើការដាំដុះដំណាំវិលជុំ(swidden)របស់ពួកគេនៅលើភ្នំនៃប្រទេសឡាវបាន។ សម្រាប់ពួកគេទន្លេនេះមិនមែនជាព្រំដែនជាតិយ៉ាងខ្លាំងខ្លានោះទេ វាគ្រាន់តែជាអ្វីដែលត្រូវឆ្លងកាត់យ៉ាងសមញ្ញទៅវិញ។

## ២. ជំនឿខាងវិញ្ញាណនិងទន្លេ

ទន្លេមេគង្គនិងទន្លេដទៃទៀតនៅក្នុងតំបន់ គឺមានមានសារៈសំខាន់ខាងវិញ្ញាណពិសេសសម្រាប់មនុស្សទាំងនោះផងដែរ។ នៅក្នុងប្រទេសថៃ,ឡាវនិងកម្ពុជា មានប្រាសាទពុទ្ធសាសនានិងវត្តអារាមនានាដែលជាទីកន្លែងនៃជំនឿរបស់មនុស្សត្រូវបានកសាងឡើងជាញឹកញាប់នៅតាមបណ្តោយមាត់ទន្លេ។ ក្នុងអំឡុងពេលនៃការសិក្សាតាមមូលដ្ឋាននេះ មានឱកាសជាញឹកញាប់ឮរឿងព្រេងនិទានជាច្រើន។ ឧទហរណ៍នៅភាគខាងត្បូងប្រទេសឡាវវាត្រូវបានគេដំណាលថាមានវាំងសត្វនាគនៅខាងក្រោមនៃទន្លេមេគង្គ។ វាត្រូវបានគេជឿថាមានព្រលឹងដ៏រឹងមាំរស់នៅក្នុងទន្លេនិងនៅកន្លែងពិសេសផ្សេងទៀតដូច្នេះវាអាចនឹងមានគ្រោះថ្នាក់ដល់ដំណើរការទូកនេសាទឬការឆ្លងកាត់ទីតាំងដែលមិនបានធ្វើការឧទ្ទិសបួងសួង។ តាមបណ្តោយទន្លេដមណូយ(DOM Noi)នៅក្នុងប្រទេសថៃដែលជាដៃនៃ ទន្លេមូន (Mun) មួយ វាគឺជាដៃនៃទន្លេមេគង្គ មនុស្សតែងតែសុំការអនុញ្ញាតពីព្រលឹង ឬអារក្ស មុនពេលនេសាទ។ គួរបញ្ជាក់ផងដែរនៅក្នុងប្រទេសថៃនិងប្រទេសឡាវត្រូវបាននិយាយយ៉ាងទូលំទូលាយថាទន្លេគឺជាតំណែលនៃការប្រយុទ្ធ របស់នាគ។

ព្រះវិញ្ញាណបាននិយាយថា មានវិញ្ញាណចិតនៅក្នុងត្រី។ទោះបីជាទំហំដ៏ធំសម្បើមក្តី រឺតូចក្តីត្រូវបានគេស្គាល់អំពីជីវិតត្រីឆ្លាំងយក្សរបស់មេគង្គត្រីទឹកសាបដ៏ធំបំផុតរបស់ពិភពលោកជាមួយនឹងភាពពេញវ័យមានទំងន់រហូតដល់ ៣០០គឡូក្រាមឯណោះ។ វាត្រូវបានគេមានជំនឿដោយសហគមន៍នេសាទថៃទោះជាយ៉ាងណាក៏ដោយ ជីវិតត្រីឆ្លាំងយក្សរស់នៅដោយសារសមាទានសីលព្រះពុទ្ធនិងភាពពិសិដ្ឋរបស់វាគឺដោយសារតែ មានស្លែនិងបន្លែផ្សេងទៀតត្រូវបានគេធ្លាប់រកឃើញនៅក្នុងពោះរបស់វាតែប៉ុណ្ណោះ។ នៅក្នុងប៉ែកតព្វសាន្ត ខេត្តអាណាបូ រាចាថានី(UbonRatchathani)របស់ប្រទេសថៃវាត្រូវបានគេជឿថានៅពេលដែលត្រីនេះត្រូវបានគេចាប់នៅក្នុងសំណាញ់របស់នរណាម្នាក់គឺជារឿងមិនសូវល្អនោះទេ។ ឥឡូវត្រីទាំងនេះអាចត្រូវបានគេលក់សម្រាប់ថវិការយ៉ាងច្រើន ប៉ុន្តែដោយសារតែមានការភ័យខ្លាចនៃការបាត់បង់ជីវិតរបស់មនុស្សម្នាក់ៗចំពោះការប្រព្រឹត្តអំពើបាបនៃការសំលាប់ត្រី អ្នកនេសាទបានអនុវត្តបន្តជាផ្លូវការសេវារំឭកព្រះពុទ្ធសាសនា បន្ទាប់ពីការលក់ត្រីឆ្លាំងយក្ស។...



ទន្លេនេះក៏ជាទីកន្លែងនៃពិធីបុណ្យផ្សេងៗ។

ជារៀងរាល់ឆ្នាំមានការប្រណាំងទូកនៅលើទន្លេមេគង្គនិងដៃទន្លេរបស់វានៅជុំវិញពេលរដូវវស្សាបញ្ចប់នោះ។ ដូចគ្នានេះផងដែរនៅក្នុងអំឡុងពេលចូលខែឆ្នាំថ្មីរបស់ប្រជាពលរដ្ឋថៃនិងឡាវនៅខែមេសា។

មនុស្សដែលប្រារព្ធពិធីនៅតាមបណ្តោយដងច្រាំងទន្លេបានកសាងប៉មដីខ្សាច់នៅលើចេតិយព្រះពុទ្ធសាសនា។ ពិធីនេះបានធ្វើឡើងនៅក្នុងទីតាំងបេតិកភណ្ឌពិភពលោកនៃហ្លួងព្រះបាងតដែលមានឈ្មោះល្បីផងដែរប៉ុន្តែទំនៀមទម្លាប់ស្រដៀងគ្នានេះត្រូវបានអង្កេតផងដែរនៅក្នុងតំបន់ដែលបានស្គាល់តិចជាងដូចជាទន្លេមុន(Mun)ជាដៃទន្លេមេគង្គមួយនៅក្នុងភាគឦសាននៃប្រទេសថៃនិង ទន្លេសេកុងនៃប្រទេសកម្ពុជា។

## ៣.ការប្រើប្រាស់ទន្លេថ្មី

នៅលើខ្ពង់រាបបូឡាវេន(Bolaven)នៃប្រទេសឡាវមានការប្រើប្រាស់កើនឡើងនៃការបង្កើតវារីអគ្គិសនីខ្នាតតូចដោយប្រើម៉ាស៊ីនភ្លើងអគ្គីសនីតូចរបស់ប្រទេសចិន។ ម៉ាស៊ីនទាំងនេះត្រូវបានលក់នៅលើទីផ្សារក្នុងស្រុកនិងអ្នកភូមិខ្លួនឯងផ្ទាល់អាចដំឡើងឧបករណ៍ដ៏សាមញ្ញនិងងាយស្រួលនេះប្រសិនបើមានគ្រួសារមួយចំនួនធ្វើការវិនិយោគរួមគ្នា ចំណាយប្រាក់ប្រហែល២០០-៣០០ដុល្លារអាមេរិក។ ការធ្លាក់ចុះនៃ កំពស់ទឹក ២ម៉ែត្រ គឺគ្រប់គ្រាន់ដើម្បីបង្កើតអគ្គិសនីបាន។ ដូច្នេះទោះបីជាគ្មានការផ្តល់ជំនួយក៏ដោយ អ្នកភូមិអាចប្រើប្រាស់ធនធានផ្ទាល់ខ្លួនរបស់ពួកគេដើម្បីទទួលបាននិងរក្សាថាមពលអគ្គីសនី។ ក្នុងភូមិដែលគ្មានអគ្គីសនីនៅក្នុងប្រទេសឡាវមានប្រជាជនខ្លះបានបង្កើតអាជីវកម្មសាកអាគុយដែលជាការផ្តល់កំណើតដល់អាជីវកម្មខ្នាតតូច។


<u>ឯកសារយោង:</u>

Mekong River Commission (MRC). 2010. *State of the Basin Report 2010.*

http://www.mrcmekong.org/assets/Publications/basin-reports/MRC-SOB-report-2010full-report.pdf


ឃិគូឈិយុកា